ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១០៥៩ ......សហវ.ប្រក

# ប្រកាស
# ស្តីពី
# ការបង្កើតគណៈកម្មការចម្រុះ
# ទទួលបន្ទុកគម្រោងការបើកផ្តល់បៀវត្សតាមប្រព័ន្ធធនាគារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹតលេខ២០ អនក្រ/បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងប្រព្រឹត្តិទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- យោងតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## <u>សម្រេច</u>

**ប្រការ ១**: បង្កើតគណៈកម្មការចម្រុះមួយក្រុម ដោយមានសមាសភាពមកពីៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមុខងារសាធារណៈ ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ក្រសួងអប់រំ យុវជននិងកីឡា ក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា និងធនាគារជាតិនៃកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តម **ជុំ គឹមឡេង** | រដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២- ឯកឧត្តម **ចេង្ស ម៉ិនឥន្ទ្រាខុច** | អគ្គនាយក នៃអគ្គនាយកដ្ឋានរតនាគារជាតិ | អនុប្រធាន |
| ៣- ឯកឧត្តម **យក់ ម៉ិនណា** | រដ្ឋលេខាធិការ នៃក្រសួងមុខងារសាធារណៈ | សមាជិក |
| ៤- ឯកឧត្តម **ឡៀម សុគន្ធ** | អនុរដ្ឋលេខាធិការ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៥- លោកជំទាវវេជ្ជបណ្ឌិត **យក់ សម្បត្តិ** | អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ នៃក្រសួងសុខាភិបាល | សមាជិក |
| ៦- ឯកឧត្តម **ថោង ប៊ុរ៉ាន់** | អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ នៃក្រសួងអប់រំ យុវជននិងកីឡា | សមាជិក |

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

| | | |
|---|---|---|
| ៧- ឧត្តមសេនីយ៍ទោ **សុខ វណ្ណារ៉ា** | អគ្គនាយករង អគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ នៃក្រសួងការពារជាតិ | សមាជិក |
| ៨- ឯកឧត្តម **សេខ យូអ៊ាន់** | អគ្គនាយករងនិងជាប្រធាននាយកដ្ឋានផែនការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ(ផ្នែករដ្ឋបាលស៊ីវិល) នៃក្រសួងមហាផ្ទៃ | សមាជិក |
| ៩- ឯកឧត្តមឧត្តមសេនីយ៍ឯក **ជា ចន្ថា** | ប្រធាននាយកដ្ឋានផែនការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ផ្នែកសន្តិសុខសាធារណៈ) នៃក្រសួងមហាផ្ទៃ | សមាជិក |
| ១០- លោកស្រី **គាំ គណ្ឋា** | ប្រធាននាយកដ្ឋានប្រតិបត្តិការ នៃធនាគារជាតិនៃកម្ពុជា | សមាជិក |

**ប្រការ ២**: គណៈកម្មការចម្រុះទទួលបន្ទុកគម្រោងការបើកផ្តល់បៀវត្សតាមប្រព័ន្ធធនាគារ មានភារកិច្ចដូចខាងក្រោម៖

- ពិនិត្យ សិក្សា និងរៀបចំផែនការសកម្មភាពគ្រប់ជ្រុងជ្រោយនិងជាជំហានៗ ព្រមទាំងកំណត់ពេលវេលាអនុវត្ត ដើម្បីជានាការអនុវត្តដោយរលូន និងសម្រេចឲ្យបានលទ្ធផលចុងក្រោយតាមការគ្រោងទុក គឺការបើកផ្តល់បៀវត្សជូនមន្ត្រីរាជការទាំងអស់តាមប្រព័ន្ធធនាគារ
- សម្របសម្រួលជាមួយធនាគារជាដៃគូ ក្នុងការរៀបចំអនុស្សរណៈនៃការយោគយល់គ្នាមួយ ស្តីពីកិច្ចដំណើរការ នៃកិច្ចប្រតិបត្តិការសេវាប្រាក់បៀវត្សតាមប្រព័ន្ធធនាគារ
- ផ្សព្វផ្សាយជូនមន្ត្រីរាជការទូទាំងប្រទេស ដើម្បីឲ្យអនុវត្តការបើកផ្តល់ប្រាក់បៀវត្សតាមប្រព័ន្ធធនាគារ
- រៀបចំយន្តការដោះស្រាយបញ្ហាបច្ចេកទេសនិងសម្រួលដល់ការបើកប្រាក់បៀវត្សតាមប្រព័ន្ធធនាគារ
- ត្រូវប្រជុំពិភាក្សា ដើម្បីស្វែងរកការឯកភាពគ្នានូវរាល់កិច្ចការទាំងឡាយ មុនដាក់ជូនថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពិនិត្យនិងសម្រេច។

**ប្រការ ៣**: អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយកដ្ឋានពាក់ព័ន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមុខងារសាធារណៈ ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ក្រសួងអប់រំ យុវជននិងកីឡា ក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា និងធនាគារជាតិនៃកម្ពុជា ព្រមទាំងសាមីខ្លួន ដូចប្រការ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ឲ្យមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ. ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១៣

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- រាជកិច្ច
  "ដើម្បីផ្សព្វផ្សាយ"